# សិក្ខាសាលាបណ្តុះបណ្តាលថ្នាក់តំបន់ ស្តីពីបន្សុាំនឹងការប្រែប្រួលអាកាសធាតុសម្រាប់
# បណ្តាប្រទេសអភិវឌ្ឍតិចតួចនៅអាស៊ី ថ្ងៃទី ២០-២៤ សីហា
# និងកិច្ចប្រជុំលើកទី ២៤ របស់ក្រុមជំនាញការនៃបណ្តាប្រទេសអភិវឌ្ឍតិចតួច
# ថ្ងៃទី ២៦-២៩ សីហា ២០១៣

# សេចក្តីប្រកាសព័ត៌មាន

មានភស្តុតាងវិទ្យាសាស្ត្រកាន់តែច្បាស់ ដែលបញ្ជាក់ថា ការប្រែប្រួលអាកាសធាតុពិតជាកើតមានយ៉ាងពិត ប្រាកដ ហើយប្រទេសអភិវឌ្ឍតិចតួចជាអ្នកដែលប្រឈមនឹងបញ្ហានេះច្រើនជាងគេ ដោយសារតែសមត្ថភាពរបស់ពួកគេមានកំរិត។

ក្រុមជំនាញការនៃបណ្តាប្រទេសអភិវឌ្ឍតិចតួចក្រោមអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួល អាកាសធាតុ មានសមាជិកជាអ្នកជំនាញការចំនួន ១៣ នាក់ក្នុងនោះ ៦ នាក់មកពីក្រុមប្រទេសអភិវឌ្ឍ តិចតួចនៃទ្វីបអាហ្វ្រិក ២ នាក់មកពីប្រទេសកូនកោះសមុទ្រប៉ាស៊ីហ្វិក ២ នាក់មកពីអាស៊ី និង ៣ នាក់ទៀតតំណាងឲ្យប្រទេសអភិវឌ្ឍន៍ (ហុល្លង់ ហ្វាំងឡង់ និង ណរវេស)។ ក្រុមជំនាញការនេះ ជាអ្នកផ្តល់ការគាំទ្របច្ចេកទេស និងការណែនាំដល់បណ្តាប្រទេសអភិវឌ្ឍតិចតួច ក្នុងការចាត់វិធានការបន្សុាំនឹងការប្រែប្រួលអាកាសធាតុ នៅថ្នាក់ជាតិ តាមរយៈយន្តការមួយចំនួន។

សិក្ខាសាលាបណ្តុះបណ្តាលថ្នាក់តំបន់ ស្តីពីបន្សុាំនឹងការប្រែប្រួលអាកាសធាតុសម្រាប់បណ្តាប្រទេសអភិវឌ្ឍតិចតួចនៅអាស៊ីថ្ងៃនេះគឺជាផ្នែកមួយនៃសិក្ខាសាលាចំនួន ៤ ដែលរៀបចំឡើងដោយក្រុមជំនាញការនៃបណ្តាប្រទេសអភិវឌ្ឍតិចតួច សម្រាប់ឆ្នាំ ២០១២-២០១៣ (១ សម្រាប់ប្រទេសអភិវឌ្ឍតិចតួចនៅអាស៊ី ១ សម្រាប់ប្រទេសអភិវឌ្ឍតិចតួចនិយាយភាសាអង់គ្លេសនៅអាហ្វ្រិក ១ សម្រាប់ប្រទេសអភិវឌ្ឍតិចតួចនិយាយភាសាបារាំងនៅអាហ្វ្រិក និង ១ ទៀតសម្រាប់ប្រទេសអភិវឌ្ឍតិចតួចនៅប៉ាស៊ីហ្វិក)។

សិក្ខាសាលានេះមានគោលបំណងកសាង និងពង្រឹងសមត្ថភាពប្រទេសអភិវឌ្ឍតិចតួច ក្នុងកិច្ចខិតខំបន្សុាំនឹងការប្រែប្រួលអាកាសធាតុ នៅថ្នាក់ជាតិ តាមរយៈកម្មវិធីសកម្មភាពជាតិឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ និងដំណើរការថ្មីមួយឈ្មោះ ផែនការបន្សុាំជាតិ។ សិក្ខាសាលានេះក៏នឹងផ្តល់ជូនផងដែរនូវវេទិកាសម្រាប់ចែករំលែកបទពិសោធន៍ ទម្លាប់ប្រតិបត្តិល្អៗ និងមេរៀនដែលទទួលបាននៅថ្នាក់តំបន់។

ក្រុមជំនាញការនៃបណ្តាប្រទេសអភិវឌ្ឍតិចតួចបំពេញការងារយ៉ាងជិតស្និទ្ធជាមួយទីភ្នាក់ងារនានារបស់អង្គការសហប្រជាជាតិ ក៏ដូចជាមជ្ឈមណ្ឌលថ្នាក់តំបន់ និងបណ្តាញការងារនានា សំដៅធានាផ្តល់នូវការគាំទ្រប្រសើរជាងមុនដល់បណ្តាប្រទេសអភិវឌ្ឍតិចតួច ក្នុងការបន្សុាំនឹងការប្រែប្រួលអាកាសធាតុ។ បណ្តាប្រទេសអភិវឌ្ឍតិចតួចបានបញ្ចប់នូវការរៀបចំកម្មវិធីសកម្មភាពជាតិបន្សុាំនឹងការប្រែប្រួលអាកាសធាតុ ហើយបច្ចុប្បន្នកំពុងតែមមារញឹកក្នុងការអនុវត្តបណ្តាគម្រោងបន្សុាំនានា សំដៅជួយដល់បណ្តាសហគមន៍ងាយរងគ្រោះ ក៏ដូចជាប្រព័ន្ធនានា ក្នុងការឆ្លើយតបនឹងផលប៉ះពាល់អវិជ្ជមាននៃការប្រែប្រួលអាកាសធាតុ។ ក្រុមជំនាញការនៃបណ្តាប្រទេសអភិវឌ្ឍតិចតួចជឿជាក់ថា សិក្ខាសាលាថ្ងៃនេះនឹងបន្តជួយគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់បណ្តាប្រទេស អភិវឌ្ឍតិចតួច ក្នុងការពុះពារជំនះនូវបញ្ហាប្រឈមនានាពីការ ប្រែប្រួលអាកាសធាតុ។